## ២.២.៣ អនុវិស័យ ការអប់រំមធ្យមសិក្សា និងអប់រំបច្ចេកទេស

### ក. លទ្ធផលសម្រេចបាន

### ក.១ ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ការអភិវឌ្ឍយុវជន និងការលើកកម្ពស់វិស័យកីឡា

#### ក.១.១ ផ្នែកបរិមាណវិស័យ

#### អនុវិទ្យាល័យរដ្ឋ និងឯកជន

អនុវិទ្យាល័យរដ្ឋថយពី ១ ២៤៤ មកត្រឹម ១ ២៤២ ដោយអនុវិទ្យាល័យមួយចំនួនបានពង្រីកទៅជាវិទ្យាល័យ។ អនុវិទ្យាល័យឯកជនបានកើនពី ៣៤ ដល់ ៩៩។

*ប្រការនេះ បានឆ្លើយតបទៅនឹងគោលនយោបាយឃុំ សង្កាត់១ អនុវិទ្យាល័យ១។ ចំនួនឃុំ សង្កាត់ ដែលមានអនុវិទ្យាល័យ១ យ៉ាងតិចមាន ១ ៥៤៥ ក្នុងចំណោមឃុំ សង្កាត់ ១ ៦៥២[1]។*

#### រូបភាពទី៧៦៖ ចំនួនអនុវិទ្យាល័យរដ្ឋ និងឯកជន ពីឆ្នាំសិក្សា២០១៣-២០១៤ ដល់ ២០២៣-២០២៤



| | ២០១៣-១៤ | ២០១៤-១៥ | ២០១៥-១៦ | ២០១៦-១៧ | ២០១៧-១៨ | ២០១៨-១៩ | ២០១៩-២០ | ២០២០-២១ | ២០២១-២២ | ២០២២-២៣ | ២០២៣-២៤ |
|---|---|---|---|---|---|---|---|---|---|---|---|
| អនុវិទ្យាល័យរដ្ឋ | ១២៤៤ | ១២៤៩ | ១២៥១ | ១២៤៨ | ១២៣៧ | ១២៤៦ | ១២៤៧ | ១២៤៦ | ១២៥៣ | ១២៤៨ | ១២៤២ |
| អនុវិទ្យាល័យឯកជន | ៣៤ | ៤៦ | ៤៣ | ៤៨ | ៦៦ | ៧៨ | ៨៧ | ៦២ | ១១២ | ៩២ | ៩៩ |

*ប្រភព៖ ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ*

#### វិទ្យាល័យរដ្ឋ និងឯកជន

វិទ្យាល័យរដ្ឋកើនពី ៤៤៤ ដល់ ៥៨១ ដោយឆ្នាំសិក្សានីមួយៗមានការបង្កើត និងពង្រីកពីអនុវិទ្យាល័យទៅវិទ្យាល័យ (វិទ្យាល័យធនធាន កើនពី ៣៦ ដល់ ៦៧ និងវិទ្យាល័យអប់រំពិសេសកើនពី ៥ ដល់ ៦)។ វិទ្យាល័យដែលមានកម្រិតថ្នាក់ទី៧ ដល់ថ្នាក់ទី១២ កើនពី ៤១៥ ដល់ ៥៤៦ និងកម្រិតថ្នាក់ទី១០ ដល់ទី១២ កើនពី ២៩ ដល់៣៥។ ស្រុក ១ លើ ២០៤ មិនទាន់មានវិទ្យាល័យ គឺស្រុកអូរគ្រៀងសែនជ័យ ខេត្តក្រចេះ។

វិទ្យាល័យឯកជនកើនពី ៨៧ ដល់ ៣១៦។ កត្តានេះបានបង្ហាញថាវិស័យឯកជន បានចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការបណ្តុះបណ្តាលធនធានមនុស្សសម្រាប់វិស័យអប់រំនៅមធ្យមសិក្សា។

#### រូបភាពទី៧៧៖ ចំនួនវិទ្យាល័យរដ្ឋ និងឯកជន ពីឆ្នាំសិក្សា២០១៣-២០១៤ ដល់ ២០២៣-២០២៤



| | ២០១៣-១៤ | ២០១៤-១៥ | ២០១៥-១៦ | ២០១៦-១៧ | ២០១៧-១៨ | ២០១៨-១៩ | ២០១៩-២០ | ២០២០-២១ | ២០២១-២២ | ២០២២-២៣ | ២០២៣-២៤ |
|---|---|---|---|---|---|---|---|---|---|---|---|
| វិទ្យាល័យរដ្ឋ | ៤៤៤ | ៤៥៥ | ៤៦៣ | ៤៨៦ | ៥១១ | ៥២៥ | ៥៤៤ | ៥៥៤ | ៥៥៩ | ៥៧១ | ៥៨១ |
| វិទ្យាល័យឯកជន | ៨៧ | ៨៦ | ១០៨ | ១២៩ | ១២២ | ១៤៧ | ១៧១ | ១៨៧ | ២១១ | ២៤៥ | ៣១៦ |

*ប្រភព៖ ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ*

---

[1] *អនុក្រឹត្យលេខ ១៦៧ អនក្រ.បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១*

## សាលារៀនជំនាន់ថ្មី

សាលារៀនជំនាន់ថ្មីកើនពី ១ នៅឆ្នាំសិក្សា២០១៤-២០១៥ ដល់ ៩ នៅឆ្នាំសិក្សា២០២៣-២០២៤។ សិស្សកើនពី ២៨២នាក់ ស្រី ១៤២នាក់ ដល់ ៦ ៧៦៦នាក់ ស្រី ៣ ៦៣០នាក់។

### រូបភាពទី៧៨៖ ចំនួនសាលារៀនជំនាន់ថ្មីពីឆ្នាំសិក្សា២០១៤-២០១៥ ដល់ ២០២៣-២០២៤



| | ២០១៤-១៥ | ២០១៥-១៦ | ២០១៦-១៧ | ២០១៧-១៨ | ២០១៨-១៩ | ២០១៩-២០ | ២០២០-២១ | ២០២១-២២ | ២០២២-២៣ | ២០២៣-២៤ |
|---|---|---|---|---|---|---|---|---|---|---|
| ចំណុចដៅ | | | | | ៦ | ៧ | ៨ | ៩ | ៧ | ១១ |
| ដាក់ស្តែង | ១ | ២ | ៣ | ៧ | ៧ | ៧ | ៧ | ៧ | ៧ | ៩ |

*ប្រភព៖ ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ*

## បុគ្គលិកអប់រំមធ្យមសិក្សា

បុគ្គលិកអប់រំនៅមធ្យមសិក្សាមាន ៥២ ៩១៤នាក់ កើន ៦ ៩៦៨នាក់ ក្នុងនោះមធ្យមសិក្សាបឋមភូមិមាន ៣៤ ១៩៧នាក់ កើន ១ ៥៨១នាក់ និងមធ្យមសិក្សាទុតិយភូមិមាន ១៨ ៧១៧នាក់ កើន ៥ ៣៨៧នាក់។ បុគ្គលិកអប់រំមានការកើនឡើងស្របតាមកំណើនសិស្ស ទាំងនៅមធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ។

### រូបភាពទី៧៩៖ បុគ្គលិកអប់រំនៅគ្រឹះស្ថានមធ្យមសិក្សា ពីឆ្នាំសិក្សា២០១៣-២០១៤ ដល់២០២៣-២០២៤



| | ២០១៣-១៤ | ២០១៤-១៥ | ២០១៥-១៦ | ២០១៦-១៧ | ២០១៧-១៨ | ២០១៨-១៩ | ២០១៩-២០ | ២០២០-២១ | ២០២១-២២ | ២០២២-២៣ | ២០២៣-២៤ |
|---|---|---|---|---|---|---|---|---|---|---|---|
| បុគ្គលិក - សរុប | ៤៥៩៤៦ | ៤៦៥៨០ | ៤៧៥៩៨ | ៤៨២២០ | ៤៨៣៥៧ | ៤៩៣៩៩ | ៥០០៦២ | ៥១១៩៣ | ៥១៥៧៥ | ៥២១០៧ | ៥២៩១៤ |
| បុគ្គលិក បឋមភូមិ | ៣២៦១៦ | ៣២៥២៥ | ៣៣១៦៤ | ៣៣៧៦៣ | ៣៣១៨១ | ៣៣៦៣៨ | ៣២៦២០ | ៣៣២៧៤ | ៣៣៣៨៦ | ៣៣៦៥៣ | ៣៤១៩៧ |
| បុគ្គលិក ទុតិយភូមិ | ១៣៣៣០ | ១៤០៥៥ | ១៤៤៣៤ | ១៤៤៥៧ | ១៥១៧៦ | ១៥៧៦១ | ១៧៤៤២ | ១៧៨៧៩ | ១៨១៨៩ | ១៨៤៥៤ | ១៨៧១៧ |

*ប្រភព៖ ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ*

## សិស្សមធ្យមសិក្សាបឋមភូមិ

សិស្សមធ្យមសិក្សាបឋមភូមិកើនពី ៥៣៨ ៦២៦នាក់ ស្រី ២៦៧ ៧៧៣នាក់ នៅឆ្នាំសិក្សា ២០១៣-២០១៤ ដល់ ៦៦២ ២៨៣នាក់ ស្រី ៣៤៥ ៣៩៧នាក់ នៅឆ្នាំសិក្សា២០២៣-២០២៤។

### រូបភាពទី៨០៖ ចំនួនសិស្សមធ្យមសិក្សាបឋមភូមិ ពីឆ្នាំសិក្សា២០១៣-២០១៤ ដល់ ២០២៣-២០២៤



| | ២០១៣-១៤ | ២០១៤-១៥ | ២០១៥-១៦ | ២០១៦-១៧ | ២០១៧-១៨ | ២០១៨-១៩ | ២០១៩-២០ | ២០២០-២១ | ២០២១-២២ | ២០២២-២៣ | ២០២៣-២៤ |
|---|---|---|---|---|---|---|---|---|---|---|---|
| សរុប | ៥៣៨៦២៦ | ៥៤៦៨៦៤ | ៥៥៨៦២១ | ៥៨៥៩៧១ | ៦០៥១៧៣ | ៦៣៨៧១២ | ៦៥៥០៨៥ | ៦៦៨៦៣៧ | ៧០៣០០៥ | ៦៩៤១៦១ | ៦៦២២៨៣ |
| ស្រី | ២៦៧៧៧៣ | ២៧៥២២២ | ២៨៥៤៧៨ | ៣០៣៦៤៥ | ៣១៤៧១៣ | ៣៣៣០៣៦ | ៣៤៤០៥០ | ៣៥៤៣១៣ | ៣៦៩៣៥១ | ៣៦២៦៥៥ | ៣៤៥៣៩៧ |

*ប្រភព៖ ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ*

## សិស្សអាហារូបករណ៍សិស្សក្រីក្រមធ្យមសិក្សាបឋមភូមិ

ចំនួនសិស្សនៅមធ្យមសិក្សាបឋមភូមិទទួលបានអាហារូបករណ៍បានកើនឡើងពី ៥៩ ៩៧១នាក់ នៅឆ្នាំសិក្សា ២០១៣-២០១៤ ដល់ ១០២ ៣៥៩ នៅឆ្នាំសិក្សា ២០២៣-២០២៤។ រូបភាពទី៨១ បង្ហាញពីការអនុវត្តយុទ្ធសាស្ត្រផ្តោតលើសមធម៌នៃការចូលរៀន និងការខិតខំប្រឹងប្រែងរបស់ក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងដៃគូអភិវឌ្ឍក្នុងការផ្តល់ឱកាសឱ្យសិស្សរៀនចប់បឋមសិក្សា បានចូលរៀននៅមធ្យមសិក្សាបឋមភូមិប្រកបដោយសមធម៌ និងបរិយាបន្ន។

**រូបភាពទី៨១៖ ចំនួនសិស្សអាហារូបករណ៍សិស្សក្រីក្រមធ្យមសិក្សាបឋមភូមិពីឆ្នាំសិក្សា២០១៣-២០១៤ ដល់ ២០២៣-២០២៤**



| | ២០១៣-១៤ | ២០១៤-១៥ | ២០១៥-១៦ | ២០១៦-១៧ | ២០១៧-១៨ | ២០១៨-១៩ | ២០១៩-២០ | ២០២០-២១ | ២០២១-២២ | ២០២២-២៣ | ២០២៣-២៤ |
|---|---|---|---|---|---|---|---|---|---|---|---|
| ចំនួនសិស្សទទួលអាហារូបករណ៍-បឋមភូមិ | ៥៩៩៧១ | ៧០៤៩៤ | ៦៩៥១៤ | ៧២០៧១ | ៧២០៧១ | ៧២៤១៨ | ៨០១៩៨ | ៧៩៥៦៧ | ១០២១៦៤ | ១០២២៣៦ | ១០២៣៥៩ |

*ប្រភព៖ ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ*

## សិស្សមធ្យមសិក្សាទុតិយភូមិ

សិស្សមធ្យមសិក្សាទុតិយភូមិមាន ២៦៦ ២៩៣នាក់ ស្រី ១២៧ ០៣៧នាក់ នៅឆ្នាំសិក្សា ២០១៣-២០១៤ ដល់ ៣៩៥ ៨២៩នាក់ ស្រី ២១៩ ០៤៥នាក់ នៅឆ្នាំសិក្សា២០២៣-២០២៤។

**រូបភាពទី៨២៖ ចំនួនសិស្សមធ្យមសិក្សាទុតិភូមិពីឆ្នាំសិក្សា២០១៣-២០១៤ ដល់ ២០២៣-២០២៤**



| | ២០១៣-១៤ | ២០១៤-១៥ | ២០១៥-១៦ | ២០១៦-១៧ | ២០១៧-១៨ | ២០១៨-១៩ | ២០១៩-២០ | ២០២០-២១ | ២០២១-២២ | ២០២២-២៣ | ២០២៣-២៤ |
|---|---|---|---|---|---|---|---|---|---|---|---|
| សរុប | ២៦៦២៩៣ | ២៦២០៧២ | ២៦៦៤៤៩ | ២៧៩៤៨០ | ៣០៣៨៩៣ | ៣៣៩៨៤៧ | ៣៥៨៥៥៣ | ៣៧៦៦៩២ | ៣៨៥៧៨៨ | ៤០១៦០៥ | ៣៩៥៨២៩ |
| ស្រី | ១២៧០៣៧ | ១២៨៥៩៤ | ១៣៣៦៥៧ | ១៤៣៤៦០ | ១៥៩១៧៥ | ១៨០៩៥០ | ១៩៥៦០៣ | ១៩១៩៧៣ | ២០៩៥០៨ | ២១៨៥១៦ | ២១៩០៤៥ |

*ប្រភព៖ ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ*

## សិស្សអាហារូបករណ៍សិស្សក្រីក្រមធ្យមសិក្សាទុតិយភូមិ

ចំនួនសិស្សនៅមធ្យមសិក្សាទុតិយភូមិទទួលបានអាហារូបករណ៍បានកើនឡើងពី ៣ ៦០០នាក់នាក់ នៅឆ្នាំសិក្សា ២០១៣-២០១៤ ដល់ ១១ ០៩២ នៅឆ្នាំសិក្សា២០២៣-២០២៤។ សិស្សវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស ៥០៨នាក់ ស្រី ២៧៥នាក់ ទទួលបានអាហារូបករណ៍នៅឆ្នាំសិក្សា២០២៣-២០២៤។ ប្រការនេះ បង្ហាញពីការអនុវត្តយុទ្ធសាស្ត្រផ្តោតលើសមធម៌នៃការចូលរៀន និងការខិតខំប្រឹងប្រែងរបស់ក្រសួង ព្រមទាំងដៃគូអភិវឌ្ឍក្នុងការផ្តល់ឱកាសឱ្យសិស្សរៀនចប់មធ្យមសិក្សាបឋមភូមិទៅមធ្យមសិក្សាទុតិយភូមិប្រកបដោយសមធម៌។

## អនុវិទ្យាល័យឆ្លើយតបនឹងស្តង់ដាអប្បបរមាទីកស្អាត អនាម័យ

អនុវិទ្យាល័យសម្រេចបានស្តង់ដាអប្បបរមាទឹកស្អាត អនាម័យកម្រិត២ កើនជាមធ្យម ១៩,៥ភាគរយ មានវឌ្ឍនភាពល្អប្រសើរ ដោយមានការវិនិយោគពីរាជរដ្ឋាភិបាល អង្គការដៃគូ និងសប្បុរសជននានា។

### រូបភាពទី៨៣៖ ភាគរយអនុវិទ្យាល័យឆ្លើយតបនឹងស្តង់ដាអប្បបរមាទឹកស្អាត អនាម័យពីឆ្នាំសិក្សា២០១៨-២០១៩ ដល់ ២០២៣-២០២៤



| | ២០១៨-១៩ | | | ២០១៩-២០ | | | ២០២០-២១ | | | ២០២១-២២ | | | ២០២២-២៣ | | | ២០២៣-២៤ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | កម្រិត១ | កម្រិត២ | កម្រិត៣ | កម្រិត១ | កម្រិត២ | កម្រិត៣ | កម្រិត១ | កម្រិត២ | កម្រិត៣ | កម្រិត១ | កម្រិត២ | កម្រិត៣ | កម្រិត១ | កម្រិត២ | កម្រិត៣ | កម្រិត១ | កម្រិត២ | កម្រិត៣ |
| ជាក់ស្តែង | ៤៨.៣០ | ១២.៥០ | ១.៥០ | ៥០.៣០ | ១៧.១០ | ១.១០ | ៤៧.៧០ | ២៦.៧០ | ១.៦០ | ៤៥.៦០ | ៣២.៦០ | ៣.២០ | ៤៦.៦៣ | ៣១.៩៧ | ២.៧២ | ៤៦.៦០ | ៣២.០០ | ២.៧០ |
| ចំណុចដៅ | | | | ៥៥.៤០ | ១៣.១០ | ១.៧០ | ៥៨.៩០ | ១៣.៤០ | ១.៨០ | ៦២.៥០ | ១៣.៧០ | ១.៩០ | ៦៤.០០ | ១៤.០០ | ២.០០ | ៤៩.៤ | ៤០.៤ | ៤.២ |

*ប្រភព៖ ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ*

### វិទ្យាល័យឆ្លើយតបនឹងស្តង់ដាអប្បបរមាទឹកស្អាត អនាម័យ

វិទ្យាល័យសម្រេចបានស្តង់ដាអប្បបរមាទឹកស្អាត អនាម័យកម្រិត២ កើនជាមធ្យម ១៨,៥ភាគរយ និងកម្រិត៣ កើនជាមធ្យម ៥,0ភាគរយ មានវឌ្ឍនភាពល្អប្រសើរ បង្ហាញពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល អង្គការដៃគូ និងសប្បុរសជននានា ក្នុងការជួយលើវិស័យអប់រំ។

### រូបភាពទី៨៤៖ ភាគរយវិទ្យាល័យឆ្លើយតបនឹងស្តង់ដាអប្បបរមាទឹកស្អាត អនាម័យ ពីឆ្នាំសិក្សា២០១៨-២០១៩ ដល់ ២០២៣-២០២៤



| | ២០១៨-១៩ | | | ២០១៩-២០ | | | ២០២០-២១ | | | ២០២១-២២ | | | ២០២២-២៣ | | | ២០២៣-២៤ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | កម្រិត១ | កម្រិត២ | កម្រិត៣ | កម្រិត១ | កម្រិត២ | កម្រិត៣ | កម្រិត១ | កម្រិត២ | កម្រិត៣ | កម្រិត១ | កម្រិត២ | កម្រិត៣ | កម្រិត១ | កម្រិត២ | កម្រិត៣ | កម្រិត១ | កម្រិត២ | កម្រិត៣ |
| ជាក់ស្តែង | ៤៨.៨០ | ២៤.៨០ | ១.៨០ | ៤៦.៨០ | ២៨.១០ | ២.៨០ | ៤២.៦០ | ៣៦.៥០ | ៣.១០ | ៤០.១០ | ៤០.៤០ | ៥.៤០ | ៣៣.៩៨ | ៤៣.២៦ | ៦.៨៣ | ៣៤.០០ | ៤៣.៣០ | ៦.៨០ |
| ចំណុចដៅ | | | | ៤៩.០០ | ២៦.១០ | ១.៩០ | ៤៩.៣០ | ២៦.៧០ | ១.៩០ | ៤៩.៧០ | ២៧.៤០ | ២.០០ | ៥០.០០ | ២៨.០០ | ២.០០ | ៤២.៩ | ៤២.៩ | ៦.០ |

*ប្រភព៖ ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ*

### អនុវិទ្យាល័យមានបង្គន់អនាម័យ ទឹកស្អាត កន្លែងលាងដៃ និងប្រអប់សង្គ្រោះបឋម

អនុវិទ្យាល័យមានបង្គន់អនាម័យកើន ៩,១៤ភាគរយ ទឹកស្អាតកើន ៤៦,៨ភាគរយ កន្លែងលាងដៃកើន ២៦,៥ភាគរយ និងប្រអប់សង្គ្រោះបឋមកើន ១៨,៥ភាគរយ។ លទ្ធផលនេះបង្ហាញថាមានការយកចិត្តទុកដាក់ខ្ពស់លើសុខភាព និងអនាម័យ។

### រូបភាពទី៨៥៖ ភាគរយអនុវិទ្យាល័យមានបង្គន់អនាម័យ ទឹកស្អាត កន្លែងលាងដៃ និងប្រអប់សង្គ្រោះបឋមពីឆ្នាំសិក្សា២០១៨-២០១៩ ដល់ ២០២៣-២០២៤



| | ២០១៨-១៩ | ២០១៩-២០ | ២០២០-២១ | ២០២១-២២ | ២០២២-២៣ | ២០២៣-២៤ |
|---|---|---|---|---|---|---|
| បង្គន់អនាម័យ | ៩០.៨៦ | ៩៩.២០ | ១០០ | ៩៩.៨០ | ៩៩.៩០ | ១០០ |
| ទឹកស្អាតសម្រាប់ទទួលទាន | ៤២.៦០ | ៨៦.៥០ | ៨៩.៦០ | ៨៣.៦០ | ៧៩.៥០ | ៨៩.៤ |
| កន្លែងលាងសម្អាតដៃ | | ៥៥.៣០ | ៨០.២០ | ៨៣.៩០ | ៨៤.១០ | ៨១.៨ |
| ប្រអប់សង្គ្រោះបឋម | | ៣៨.៣០ | ៤៥.៣០ | ៤៤.៨០ | ៤៥.៣០ | ៥៦.៨ |

*ប្រភព៖ ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ*

### វិទ្យាល័យមានបង្គន់អនាម័យ ទឹកស្អាត កន្លែងលាងដៃ និងប្រអប់សង្គ្រោះបឋម

វិទ្យាល័យមានបង្គន់អនាម័យកើន ៤,៥ភាគរយ ទឹកស្អាតកើន ២៨,៥ ភាគរយ កន្លែងលាងដៃកើន ១៥,៦ភាគរយ និងប្រអប់សង្គ្រោះបឋមកើន ១៦,៧ភាគរយ។ លទ្ធផលនេះបង្ហាញថាមានការយកចិត្តទុកដាក់ខ្ពស់លើសុខភាព និងអនាម័យ។

**រូបភាពទី៨៦៖ ភាគរយវិទ្យាល័យមានបង្គន់អនាម័យ ទឹកស្អាត កន្លែងលាងដៃ និងប្រអប់សង្គ្រោះបឋម ពីឆ្នាំសិក្សា ២០១៨-២០១៩ ដល់ ២០២៣-២០២៤**



| | ២០១៨-១៩ | ២០១៩-២០ | ២០២០-២១ | ២០២១-២២ | ២០២២-២៣ | ២០២៣-២៤ |
|---|---|---|---|---|---|---|
| បង្គន់អនាម័យ | ៩៥.៥ | ៩៨.៩ | ១០០ | ១០០ | ៨៨.៦ | ១០០ |
| ទឹកស្អាតសម្រាប់ទទួលទាន | ៥៤.១ | ៨៧.៩ | ៩១.២ | ៨៦.៩ | ៨៦.៧ | ៨២.៦ |
| កន្លែងលាងសម្អាតដៃ | | ៧០.៦ | ៨៥.៤ | ៩១.៩ | ៨៧.៦ | ៨៦.២ |
| ប្រអប់សង្គ្រោះបឋម | | ៦១.៤ | ៦១.១ | ៧៣.៧ | ៧២.៥ | ៧៨.១ |

*ប្រភព៖ ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ*

## សាលាមធ្យមសិក្សាដែលមានអគ្គិសនីប្រើប្រាស់

គ្រឹះស្ថានមធ្យមសិក្សាមានអគ្គិសនីប្រើប្រាស់ ៩៨,៨ភាគរយ នៅឆ្នាំសិក្សា ២០២៣-២០២៤ ក្នុងនោះអនុវិទ្យាល័យមានអគ្គិសនីប្រើប្រាស់កើនពី ៦៩,៥ភាគរយ ដល់ ៩៧,៨ភាគរយ និងវិទ្យាល័យមានអគ្គិសនីប្រើប្រាស់កើនពី ៨៩,៣ភាគរយ ដល់ ៩៩,៨ភាគរយ។ ក្រសួងបានបន្តវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធនេះដើម្បីឱ្យសាលារៀនទាំងអស់នៅទូទាំងប្រទេសមានអគ្គិសនីប្រើប្រាស់ និងបានជួយគាំទ្រដល់ដំណើរការបង្រៀន និងរៀន។

**រូបភាពទី៨៧៖ ភាគរយសាលាមធ្យមសិក្សាដែលមានអគ្គិសនីប្រើប្រាស់ពីឆ្នាំសិក្សា២០១៨-២០១៩ ដល់ ២០២៣-២០២៤**



| | ២០១៨-១៩ | | ២០១៩-២០ | | ២០២០-២១ | | ២០២១-២២ | | ២០២២-២៣ | | ២០២៣-២៤ | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចំណុចដៅ | ជាក់ស្តែង | ចំណុចដៅ | ជាក់ស្តែង | ចំណុចដៅ | ជាក់ស្តែង | ចំណុចដៅ | ជាក់ស្តែង | ចំណុចដៅ | ជាក់ស្តែង | ចំណុចដៅ | ជាក់ស្តែង |
| អនុវិទ្យាល័យ | ៧១.០ | ៦៩.៥ | ៧២.០ | ៩៤.៣ | ៧៣.០ | ៩៣.៣ | ៧៤.០ | ៩៥.០ | ៩៥.២ | ៩៥.៩ | ៩៦.១ | ៩៧.៨ |
| វិទ្យាល័យ | ៩២.៤ | ៨៩.៣ | ៩៣.១ | ៩៨.៧ | ៩៣.៧ | ៩៨.៩ | ៩៤.៤ | ៩៩.៥ | ៩៩.៥ | ៩៩.១ | ៩៩.៧ | ៩៩.៨ |

*ប្រភព៖ ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ*

## សាលាមធ្យមសិក្សាទុតិយភូមិប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ (ICT)

សាលារៀនមធ្យមសិក្សាទុតិយភូមិបានប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ សម្រាប់គាំទ្រការបង្រៀន និងរៀន បានកើនពី ១០ភាគរយ ក្នុងឆ្នាំសិក្សា២០១៨-២០១៩ ដល់ ...........ភាគរយ នៅឆ្នាំសិក្សា២០២៣-២០២៤ (មិនមានទិន្នន័យ)។

**រូបភាពទី៨៨៖ ភាគរយសាលាមធ្យមសិក្សាទុតិយភូមិប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ (ICT) សម្រាប់គាំទ្រការបង្រៀន និងរៀន ពីឆ្នាំសិក្សា២០១៨-២០១៩ ដល់ ២០២២-២០២៣**



| | ២០១៨-២០១៩ | ២០១៩-២០២០ | ២០២០-២០២១ | ២០២១-២០២២ | ២០២២-២០២៣ | ២០២៣-២០២៤ |
|---|---|---|---|---|---|---|
| ចំណុចដៅ | ៩ | ១៣ | ១៧ | ២១ | ២៥ | ៦៦.២ |
| ជាក់ស្តែង | ១០ | ១៧ | ២៤.៦ | ១៥.៦ | ២៦.៦៨ | ០ |

## សាលាមធ្យមសិក្សាអនុវត្តកម្មវិធីការគ្រប់គ្រងតាមសាលារៀន

គ្រឹះស្ថានមធ្យមសិក្សាដែលបានអនុវត្តកម្មវិធីការគ្រប់គ្រងតាមសាលារៀន បានកើនឡើងពី១០០ នៅឆ្នាំសិក្សា ២០១៧-២០១៨ ដល់ ៥០២ នៅឆ្នាំសិក្សា២០២៣-២០២៤ ដោយក្រសួងបានសហការជាមួយដៃគូអភិវឌ្ឍរៀបចំគម្រោងកែលម្អការអប់រំនៅមធ្យមសិក្សាក្នុងក្របខណ្ឌការគ្រប់គ្រងសាលារៀនប្រកបដោយប្រសិទ្ធភាព ដោយផ្តោតលើការវាយតម្លៃលទ្ធផលសិក្សា ស្វ័យភាពក្នុងការគ្រប់គ្រង និងគណនេយ្យភាពប្រកបដោយជោគជ័យ។

**រូបភាពទី៨៩៖ ចំនួនសាលាមធ្យមសិក្សាអនុវត្តកម្មវិធីការគ្រប់គ្រងតាមសាលារៀនប្រកបដោយប្រសិទ្ធភាពពីឆ្នាំសិក្សា ២០១៧-២០១៨ ដល់ ២០២៣-២០២៤**




| | ២០១៧-១៨ | ២០១៨-១៩ | ២០១៩-២០ | ២០២០-២១ | ២០២១-២២ | ២០២២-២៣ | ២០២៣-២៤ |
|---|---|---|---|---|---|---|---|
| ជាក់ស្តែង | ១០០ | ១៦៥ | ១៩៥ | ២២៥ | ២៦០ | ៥០៦ | ៥០២ |
| ចំណុចដៅ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ៤៣៥ | ៤៥០ |

## គណៈគ្រប់គ្រងសាលាមធ្យមសិក្សា

ពីឆ្នាំសិក្សា២០១៨-២០១៩ ដល់ ២០២៣-២០២៤ គណៈគ្រប់គ្រងសាលារៀន ចំនួន ១៧៣នាក់ ដល់ ៧៤៩នាក់បានបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ ស្តីពីការគ្រប់គ្រងតាមសាលារៀន ដោយផ្ទាល់ និងពីចម្ងាយ តាមរយៈកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគណៈគ្រប់គ្រងសាលារៀន។

**រូបភាពទី៩០៖ ចំនួនគណៈគ្រប់គ្រងមធ្យមសិក្សាបានទទួលការបណ្តុះបណ្តាលលើការគ្រប់គ្រងតាមសាលារៀនពីឆ្នាំសិក្សា២០១៨-២០១៩ ដល់ ២០២៣-២០២៤**



| | ២០១៨-២០១៩ | ២០១៩-២០២០ | ២០២០-២០២១ | ២០២១-២០២២ | ២០២២-២០២៣ | ២០២៣-២០២៤ |
|---|---|---|---|---|---|---|
| ចំណុះដៅ | ១៧០ | ២០០ | ២០០ | ២០០ | ៧៩៧ | ១៤៣៥ |
| ដាក់ស្តែង | ១៧៣ | ១៨០ | ១៨០ | ៦០៥ | ៧៤៩ | ៧៤៩ |

## ការប្រែប្រួលផ្នែកប្រសិទ្ធភាពផ្ទៃក្នុង

### អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ

អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិកើនពី ៥៥,៣ភាគរយ ស្រី ៥៥,០ភាគរយ ប្រុស ៥២,១ភាគរយ នៅឆ្នាំសិក្សា ២០១៣-២០១៤ ដល់ ៦៥,៥ភាគរយ ស្រី ៦៩,៩ភាគរយ ប្រុស ៦១,៣ភាគរយ នៅឆ្នាំសិក្សា២០២៣-២០២៤ កំណើនជាមធ្យមក្នុងមួយឆ្នាំ ៤,៩១ភាគរយ ស្រី ៩,០១ភាគរយ និងប្រុស ៤,០១ភាគរយ។ កំណើននេះបញ្ជាក់ពីការយកចិត្តទុកដាក់ក្នុងការប្រមូលកុមារចូលរៀន នៅតាមសាលារៀនមានភាពល្អប្រសើរពីមួយឆ្នាំទៅមួយឆ្នាំស្របតាមស្ថានភាពសុវត្ថិភាពសង្គម។

**រូបភាពទី៩១៖ អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិពីឆ្នាំសិក្សា២០១៣-២០១៤ ដល់ ២០២៣-២០២៤**



| | ២០១៣-១៤ | ២០១៤-១៥ | ២០១៥-១៦ | ២០១៦-១៧ | ២០១៧-១៨ | ២០១៨-១៩ | ២០១៩-២០ | ២០២០-២១ | ២០២១-២២ | ២០២២-២៣ | ២០២៣-២៤ |
|---|---|---|---|---|---|---|---|---|---|---|---|
| សរុប | ៥៥.៣ | ៥៥.១ | ៥៦.៥ | ៥៧.៦ | ៥៩.២ | ៥៩.១ | ៥៩.៩ | ៦០.៧ | ៦៨.៦ | ៦៤.៨ | ៦៥.៥ |
| ស្រី | ៥៥.០ | ៥៦.២ | ៥៩.៤ | ៦១.៥ | ៦៣.៤ | ៦៣.៨ | ៦៥.១ | ៦៦.៦ | ៧៣.៨ | ៦៩.៤ | ៦៩.៩ |
| ប្រុស | ៥២.១ | ៥១.៥ | ៥៣.៨ | ៥៣.៩ | ៥៥.២ | ៥៤.៩ | ៥៥.១ | ៥៥.៣ | ៦៣.៥ | ៦០.៦ | ៦១.៣ |

*ប្រភព៖ ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ*

### អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ

អត្រាបញ្ចប់ការសិក្សាកើនពី ៣៩,០៩ភាគរយ ស្រី ៤០,០២ភាគរយ ប្រុស ៣៨,២៨ភាគរយ នៅឆ្នាំសិក្សា ២០១៣-២០៤ ដល់ ៦០,៩៧ភាគរយ ស្រី ៦៦,៣៧ភាគរយ ប្រុស ៥៥,៦៩ភាគរយ នៅឆ្នាំសិក្សា២០២៣-២០២៤ កំណើនជាមធ្យមក្នុងមួយឆ្នាំ ៩,០៦ភាគរយ ស្រី ១២,០៤ភាគរយ និងប្រុស ៦,១៦ភាគរយ ។ អត្រាបញ្ចប់ការសិក្សារបស់សិស្សស្រីខ្ពស់ជាងសិស្សប្រុស។

**រូបភាពទី៩២៖ អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ ពីឆ្នាំសិក្សា២០១៣-២០១៤ ដល់ ២០២៣-២០២៤**



| | ២០១៣-១៤ | ២០១៤-១៥ | ២០១៥-១៦ | ២០១៦-១៧ | ២០១៧-១៨ | ២០១៨-១៩ | ២០១៩-២០ | ២០២០-២១ | ២០២១-២២ | ២០២២-២៣ | ២០២៣-២៤ |
|---|---|---|---|---|---|---|---|---|---|---|---|
| សរុប | ៣៩.០៩ | ៤០.៣០ | ៣៩.២៣ | ៤៤.៤៧ | ៤៦.៤៣ | ៤៧.៦០ | ៤៧.៣០ | ៤៨.១០ | ៥៦.៥០ | ៥៩.៧០ | ៦០.៩៧ |
| ស្រី | ៤០.០២ | ៤១.៨០ | ៤១.២៧ | ៤៧.៩៤ | ៥០.៩៤ | ៥២.៦០ | ៥២.៥០ | ៥៣.៤០ | ៦១.៣០ | ៦៤.៥០ | ៦៦.៣៧ |
| ប្រុស | ៣៨.២៨ | ៣៨.៩០ | ៣៧.៣៣ | ៤១.២២ | ៤២.២០ | ៤២.៩០ | ៤២.៤០ | ៤៣.១០ | ៥១.៩០ | ៥៤.៩០ | ៥៥.៦៩ |

*ប្រភព៖ ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ*

## អត្រាគង់វង្សនៅមធ្យមសិក្សាបឋមភូមិ

អត្រាគង់វង្សនៅមធ្យមសិក្សាបឋមភូមិបានបង្ហាញនូវលទ្ធផលនៃការកើនឡើង ០,៤០ភាគរយក្នុងរយៈពេលប្រាំមួយឆ្នាំ។ ប្រការនេះ បង្ហាញនូវការចូលរួមគាំទ្រពីគ្រប់ភាគីពាក់ព័ន្ធដល់ដំណើរការបង្រៀននិងរៀន។

### រូបភាពទី៩៣៖ អត្រាគង់វង្សនៅមធ្យមសិក្សាបឋមភូមិ ពីឆ្នាំសិក្សា២០១៨-២០១៩ ដល់ ២០២៣-២០២៤



| | ២០១៨-១៩ | ២០១៩-២០ | ២០២០-២១ | ២០២១-២២ | ២០២២-២៣ | ២០២៣-២៤ |
|---|---|---|---|---|---|---|
| សរុប | ៥៣.១ | ៤២.២ | ៤៣.១ | ៤៤.៦ | ៤៤.៣ | ៥៣.៥ |
| ស្រី | ៥៦.៨ | ៤៨.៩ | ៤៦.៤ | ៤៦.៧ | ៣៩.៦ | ៥៥.១ |
| ប្រុស | ៤៩.២ | ៣៨.១ | ៤០.០ | ៤២.៦ | ៤៩.៦ | ៥១.៨ |

*ប្រភព៖ ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ*

## អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ

អត្រាបោះបង់ការសិក្សាថយពី ២១,២ភាគរយ ស្រី ២០,៩ភាគរយ នៅឆ្នាំសិក្សា២០១៣-២០១៤ មកត្រឹម ១៥,៤ ភាគរយ ស្រី ១៣,៨ភាគរយ នៅឆ្នាំសិក្សា២០២៣-២០២៤ ថយជាមធ្យមក្នុងមួយឆ្នាំ ៣,៣០ភាគរយ ស្រី ៤,០៩ភាគរយ។ វឌ្ឍនភាពនេះបង្ហាញពីការគាំទ្រ និងអន្តរាគមន៍នានា ដូចជាកម្មវិធីអាហារូបករណ៍សិស្សក្រីក្រ ការពង្រឹកហេដ្ឋារចនាសម្ព័ន្ធសាលារៀន ការចូលរួមសហការពីមាតាបិតា ឬអ្នកអាណាព្យាបាល សហគមន៍ និងការពង្រឹងការដឹកនាំនិងគ្រប់គ្រងសាលារៀន។

### រូបភាពទី៩៤៖ អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ ពីឆ្នាំសិក្សា២០១៣-២០១៤ ដល់ ២០២៣-២០២៤



| | ២០១៣-១៤ | ២០១៤-១៥ | ២០១៥-១៦ | ២០១៦-១៧ | ២០១៧-១៨ | ២០១៨-១៩ | ២០១៩-២០ | ២០២០-២១ | ២០២១-២២ | ២០២២-២៣ | ២០២៣-២៤ |
|---|---|---|---|---|---|---|---|---|---|---|---|
| សរុប | ២១.២ | ២១.០ | ១៩.២ | ១៧.០ | ១៥.៤ | ១៥.៨ | ១៨.៦ | ១៨.២ | ១៦.៦ | ១៨.២ | ១៥.៤ |
| ស្រី | ២០.៩ | ២០.៣ | ១៨.២ | ១៥.៥ | ១៤.២ | ១៤.២ | ១៧.៤ | ១៦.៩ | ១៦.៣ | ១៧.២ | ១៣.៨ |
| ប្រុស | ២១.៥ | ២១.៧ | ២០.៣ | ១៨.៥ | ១៦.៦ | ១៧.៦ | ២០.០ | ១៩.២ | ១៦.៩ | ១៩.២ | ១៧.០ |

*ប្រភព៖ ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ*

## អត្រាឆ្លងភូមិសិក្សាពីមធ្យមសិក្សាបឋមភូមិទៅទុតិយភូមិ

អត្រាឆ្លងភូមិសិក្សាមធ្យមសិក្សាបឋមភូមិទៅមធ្យមសិក្សាទុតិយភូមិកើនពី ៧០,២ភាគរយ ស្រី ៧១,៤ភាគរយ ប្រុស ៦៩,១ភាគរយ នៅឆ្នាំសិក្សា២០១៣-២០៤ ដល់ ៨០,៣ភាគរយ ស្រី ៨៣,៧ភាគរយ ប្រុស ៧៦,៣ភាគរយ នៅឆ្នាំសិក្សា២០២៣-២០២៤ កំណើនជាមធ្យមក្នុងមួយឆ្នាំ ៥,៥០ភាគរយ ស្រី ៦,៦៥ភាគរយ និងប្រុស ៤,១៥ភាគរយ។ អត្រាឆ្លងភូមិសិក្សារបស់សិស្សស្រីខ្ពស់ជាងសិស្សប្រុស។

### រូបភាពទី៩៥៖ អត្រាឆ្លងភូមិសិក្សាពីមធ្យមសិក្សាបឋមភូមិទៅទុតិយភូមិ ពីឆ្នាំសិក្សា២០១៣-២០១៤ ដល់ ២០២៣-២០២៤



| | ២០១៣-១៤ | ២០១៤-១៥ | ២០១៥-១៦ | ២០១៦-១៧ | ២០១៧-១៨ | ២០១៨-១៩ | ២០១៩-២០ | ២០២០-២០២១ | ២០២១-២២ | ២០២២-២៣ | ២០២៣-២៤ |
|---|---|---|---|---|---|---|---|---|---|---|---|
| សរុប | ៧០.២ | ៧១.១ | ៧២.៤ | ៧៤.៥ | ៧៦.៨ | ៧៥.៤ | ៧៤.៩ | ៨១.៣ | ៧៨.២ | ៧៧.៦ | ៨០.៣ |
| ស្រី | ៧១.៤ | ៧២.៩ | ៧៤.៦ | ៧៧.៦ | ៧៩.២ | ៧៨.០ | ៧៨.៦ | ៨២.៤ | ៧៩.៦ | ៨០.៦ | ៨៣.៧ |
| ប្រុស | ៦៩.១ | ៦៩.៤ | ៧០.២ | ៧១.៤ | ៧៤.២ | ៧២.៧ | ៧០.៨ | ៨០.១ | ៧៦.៥ | ៧៥.១ | ៧៦.៣ |

*ប្រភព៖ ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ*

## *អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ*

អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិកើនពី ២៤,៩ភាគរយ ស្រី ២៤,៩ភាគរយ ប្រុស ២៥,២ភាគរយ នៅឆ្នាំសិក្សា២០១៣-២០១៤ ដល់ ៤៦,៧ភាគរយ ស្រី ៥២,៨ភាគរយ ប្រុស ៤០,៨ភាគរយ នៅឆ្នាំសិក្សា២០២៣-២០២៤ កំណើនជាមធ្យមក្នុងមួយឆ្នាំ ៦,៦ភាគរយ ស្រី ៩,៧ភាគរយ ប្រុស ៤,១ភាគរយ។ កំណើននេះបញ្ជាក់ពីការយកចិត្តទុកដាក់ ក្នុងការប្រមូលកុមារចូលរៀននៅតាមសាលារៀនមានភាពល្អប្រសើរ ដោយសារកំណែទម្រង់ប្រព័ន្ធអប់រំមានប្រសិទ្ធភាព និងជីវភាពប្រជាជនមានការកើនឡើង ប្រទេសមានសុខសន្តិភាព។

### រូបភាពទី៩៦៖ អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ ពីឆ្នាំសិក្សា២០១៣-២០១៤ ដល់ ២០២៣-២០២៤



| | ២០១៣-១៤ | ២០១៤-១៥ | ២០១៥-១៦ | ២០១៦-១៧ | ២០១៧-១៨ | ២០១៨-១៩ | ២០១៩-២០ | ២០២០-២១ | ២០២១-២២ | ២០២២-២៣ | ២០២៣-២៤ |
|---|---|---|---|---|---|---|---|---|---|---|---|
| សរុប | ២៤.៩ | ២៤.២ | ២៤.២ | ២៦.៥ | ២៨.៥ | ២៩.៧ | ៣០.៩ | ៣២.២ | ៣៩.៤ | ៣៩.៤ | ៤៦.៧ |
| ស្រី | ២៤.៩ | ២៤.៦ | ២៦. | ២៨.១ | ៣០.៩ | ៣២.៩ | ៣៥.១ | ៣២.៣ | ៤៣.៦ | ៤៩.២ | ៥២.៨ |
| ប្រុស | ២៥.២ | ២៣.៨ | ២៤.១ | ២៥. | ២៦.៣ | ២៦.៧ | ២៧.១ | ២៨.៥ | ៣៥.៣ | ៣៩.៣ | ៤០.៨ |

*ប្រភព៖ ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ*

## អត្រាគង់វង្សនៅមធ្យមសិក្សាទុតិយភូមិ

អត្រាគង់វង្សនៅមធ្យមសិក្សាទុតិយភូមិត្រូវបានគណនាក្នុងរយៈពេល ៦ឆ្នាំចុងក្រោយនេះ បានបង្ហាញនូវលទ្ធផលថយចុះជាមធ្យម ៦,៨១ភាគរយក្នុងមួយឆ្នាំ ។ ប្រការនេះ បង្ហាញនូវការព្រួយបារម្ភដែលតម្រូវឱ្យគ្រប់ភាគីពាក់ព័ន្ធចូលរួមយកចិត្តទុកដាក់ និងគាំទ្រដល់ដំណើរការបង្រៀននិងរៀន។

### រូបភាពទី៩៧៖ អត្រាគង់វង្សនៅមធ្យមសិក្សាទុតិយភូមិ ពីឆ្នាំសិក្សា២០១៨-២០១៩ ដល់ ២០២៣-២០២៤



| | ២០១៨-១៩ | ២០១៩-២០ | ២០២០-២១ | ២០២១-២២ | ២០២២-២៣ | ២០២៣-២៤ |
|---|---|---|---|---|---|---|
| សរុប | ៣៤.៩ | ២៤.៥ | ២៤.៧ | ២៥.២ | ២៥.១ | ៣៤.១ |
| ស្រី | ៣៨.៩ | ២៨.៩ | ២៧.០ | ២៦.៦ | ២៣.៣ | ៣៧.១ |
| ប្រុស | ៣១.០ | ២០.៥ | ២២.៦ | ២៣.៧ | ២៦.៩ | ៣០.៩ |

*ប្រភព៖ ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ*

## ក.១.២ ផ្នែកគុណវិស័យ

## ការប្រឡងសញ្ញាបត្រមធ្យមសិក្សាចំណេះទូទៅ និងបំពេញវិជ្ជា

ពីឆ្នាំសិក្សា ២០១៣-២០១៤ ដល់ ២០២៣-២០២៤ នៅមធ្យមសិក្សាបឋមភូមិ បេក្ខជនប្រឡងជាប់ កើន ០,៤២ភាគរយ និងមធ្យមសិក្សាទុតិយភូមិបេក្ខជនប្រឡងជាប់កើន ៣៨,៣៣ភាគរយ។ ដោយឡែកក្នុងឆ្នាំសិក្សា ២០១៩-២០២០ បេក្ខជនប្រឡងសញ្ញាបត្របឋមភូមិ និងទុតិយភូមិត្រូវបាន **សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** សម្រេចអនុញ្ញាតឱ្យជាប់ ១០០ភាគរយ ដោយសារការរីករាលដាលជំងឺកូវីដ១៩។

### រូបភាពទី៩៨៖ លទ្ធផលនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ពីឆ្នាំសិក្សា២០១៣-២០១៤ ដល់ ២០២៣-២០២៤



| | ២០១៣-១៤ | ២០១៤-១៥ | ២០១៥-១៦ | ២០១៦-១៧ | ២០១៧-១៨ | ២០១៨-១៩ | ២០១៩-២០ | ២០២០-២១ | ២០២១-២២ | ២០២២-២៣ | ២០២៣-២៤ |
|---|---|---|---|---|---|---|---|---|---|---|---|
| បេក្ខជនមកប្រឡង(នាក់) | ១១៧១៨២ | ១២៣៩៨២ | ១២៥៩៤៥ | ១៤១៩២៨ | ១៥០០៩៩ | ១៥៨៦៧៩ | ១៦៤៧៥៩ | ១៤៥៦៦៨ | ១៦២១៦៦ | | ១៨៦៥៣៧ |
| បេក្ខជនប្រឡងជាប់(នាក់) | ១០៩៦៤៩ | ១១៦០០៤ | ១១៨០៣០ | ១៣៤១១៩ | ១៤១៤១០ | ១៤៤៣៦៥ | ១៦៤៧៥៩ | ១៤១០៥៦ | ១៥៣៦៤៩ | ១៧៣២១៦ | ១៧៥៣៥៦ |

*ប្រភព៖ នាយកដ្ឋានកិច្ចការប្រឡង*

បេក្ខជនមកប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ១៣៤ ៦២៩នាក់ ស្រី ៧៣ ៩២៩នាក់ បេក្ខជនប្រឡងជាប់ ១០៦ ៣៥១នាក់ ស្មើ ៧៩ភាគរយ ស្រី ៦១ ៥៣០នាក់ ស្មើ ៨៣,២៣ភាគរយ ក្នុងនោះបេក្ខជនមាននិទ្ទេស A ២ ២១៦នាក់ ស្រី ១ ២៨១នាក់ និទ្ទេស B ៩ ៧០១នាក់ ស្រី ៥ ៩៨៥នាក់ និទ្ទេស C ២២ ៦៧៥នាក់ ស្រី ១៤ ២២០នាក់ និទ្ទេស D ៣៦ ៦៨៣នាក់ ស្រី ២១ ៦៩៨នាក់ និងនិទ្ទេស E ៣៥ ០៧៦នាក់ ស្រី ១៨ ៣៤៦នាក់។ បើធៀបទៅនឹងឆ្នាំ២០២១ មាន ៦៥,៦៥ភាគរយ បេក្ខជនទិទ្ទេស A មាន ១ ៧៥៣នាក់ ស្រី ១ ០៥១នាក់ និទ្ទេស B មាន ៥ ២១៥នាក់ ស្រី ៣១២១នាក់ និទ្ទេស C មាន ១១ ៦៣៤នាក់ ស្រី ៧ ២៣១នាក់ ទិទ្ទេស D មាន ២៣ ៤៩៩នាក់ ស្រី ១៤ ២២១នាក់ និងនិទ្ទេស E មាន ២៩ ៩១៥នាក់ ស្រី ១៦ ១២៦នាក់។

### រូបភាពទី៩៩៖ លទ្ធផលនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ពីឆ្នាំសិក្សា២០១៣-២០១៤ ដល់ ២០២៣-២០២៤



| | ២០១៣-១៤ | ២០១៤-១៥ | ២០១៥-១៦ | ២០១៦-១៧ | ២០១៧-១៨ | ២០១៨-១៩ | ២០១៩-២០ | ២០២០-២១ | ២០២១-២២ | ២០២២-២៣ | ២០២៣-២៤ |
|---|---|---|---|---|---|---|---|---|---|---|---|
| បេក្ខជនមកប្រឡង(នាក់) | ៨៣៥៩៩ | ៨៣៣២៥ | ៨៩៦៦១ | ៩៩៧២៨ | ១១៣៣៦៥ | ១១៥២០៦ | ១២១០៧៤ | ១០៩៦៩៥ | ១២៥៧៣៥ | ១៣៥០៧២ | ១៣៤៦២៩ |
| បេក្ខជនប្រឡងជាប់(នាក់) | ៣៣៩៩៧ | ៤៦៥៦០ | ៥៥៧៥៣ | ៦៣៦៦៨ | ៧៦០៣៤ | ៧៩០៥២ | ១២១០៧៤ | ៧២០៦៤ | ៩០៩៥០ | ៩៨៤៦០ | ១០៦៣៥១ |

*ប្រភព៖ នាយកដ្ឋានកិច្ចការប្រឡង*